# សំណូមពររបស់កុមារ៖

## សំឡេងរបស់កុមារកម្ពុជាប្រយុទ្ធប្រឆាំងនិងការរំលោភបំពាន ផ្លូវភេទនៅតាមប្រព័ន្ធអនឡាញ (OCSE)

SCROL
Safety for Children and their Rights OnLine

Terre des Hommes Netherlands

## សេចក្តីផ្តើម

អង្គការដែនដីមនុស្សហូឡង់ មានបេសកកម្មការពារកុមារនៅក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអឺរ៉ុបតាមរយៈការបង្ការនិងការពារកុមារពីការកេងប្រវ័ញ្ចគ្រប់ទម្រង់ បង្កើនភាពអង់អាចដល់កុមារដោយការស្តាប់និងការទទួលយកមតិយោបល់របស់ពួកគេ។ យើងធ្វើការដោះស្រាយបញ្ហាដោយការកំណត់ពីឫសគល់នៃបញ្ហា និងបង្កើតការផ្លាស់ប្តូរជាប្រព័ន្ធ តាមរយៈការគាំទ្រអង្គការដៃគូរក្នុងការអនុវត្ត។ អង្គការយើងខ្ញុំតែងតែគិតគូរពីឧត្តមប្រយោជន៍របស់កុមារជាសំខាន់។





ដើម្បីជួយសម្រួលដល់ការចាប់ផ្តើមវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និង ឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអឡាញ ២០២១-២០២៥ យើងបានចំរៀបកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី “ការស្តាប់សំឡេងកុមារ” ។

## អង្គការដែនដីមនុស្សហូឡង់ កំពុងអនុវត្តគម្រោងសុវត្ថិភាព និងសិទ្ធិកុមារនៅលើប្រព័ន្ធអនឡាញ ដែលហៅកាត់ថា “ស្រួល” មានរយៈពេល៣ឆ្នាំមក ហើយចាប់តាំងពីខែតុលា ឆ្នាំ២០២២

ដែលបានអនុវត្តគម្រោងតាមរយៈអង្គការដៃគូចំនួន២គឺអង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam) និងអង្គការសកម្មភាពដើម្បីកុមារ(APLE) ព្រមទាំងមានកិច្ចសហការអនុវត្តគម្រោងជាមួយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) និងនាយកដ្ឋានគោលនយោបាយICT នៃក្រសួងប្រៃសណីយ៍និងទូរគមន៍ នៅប្រទេសកម្ពុជា។

ដើម្បីជួយសម្រួលដល់ការចាប់ផ្ដើមវាយតម្លៃពាក់កណ្ដាលអាណត្តិ នៃការអនុវត្តផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និង ឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអឡាញ ២០២១-២០២៥ យើងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្ដីពី “ការស្ដាប់សំឡេងកុមារ” កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលមានសមាភាពចូលរួមពីតំណាងកុមារ និងយុវជន សរុបចំនួន២០នាក់(ស្រី១៧) តំណាងអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដើម្បីទទួលយកសំណូមពររបស់កុមារតាមរយៈកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមានតួនាទីសម្របសម្រួល និងពិគ្រោះយោបល់អំពីសកម្មភាពទាំងឡាយដែលពាក់ព័ន្ធ និងបញ្ហាកុមារ។

## កិច្ចប្រជុំពិគ្រោះយោបល់នេះ បានផ្ដោតលើផែនការយុទ្ធសាស្ត្រទាំង៦ នៃផែនការសកម្មភាពដើម្បី បង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអឡាញ រួមមាន៖

១.គោលនយោបាយ និងអភិបាលកិច្ច

២.យុត្តិធម៌ព្រហ្មទណ្ឌ

៣.ការជួយជនរងគ្រោះ

៤.សុវត្ថិភាពសហគមន៍

៥.វិស័យឯកជន

៦.ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង

# សំណូមពររបស់តំណាងកុមារ និងយុវជន៖



## ១.គោលនយោបាយ និងអភិបាលកិច្ច

ពន្លឿនការអនុម័តច្បាប់ស្ដីពីកិច្ចការពារកុមារ ៖ តំណាងកុមារ និងយុវជនបានសំណូមឱ្យជំរុញការអនុម័តច្បាប់ស្ដីពីកិច្ចការពារកុមារ។

ដាក់បញ្ចូលមេរៀនសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញទៅក្នុងកម្មវិធីសិក្សា ៖ តំណាងកុមារ និងយុវជនបានសំណូមពរឱ្យក្រសួងអប់រំ យុវជន និងកីឡាដាក់បញ្ចូលមេរៀនសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញទៅក្នុងកម្មវិធីសិក្សាទូទាំងប្រទេស។

សម្រួលការប្រើប្រាស់ពាក្យគន្លឹះ ៖ តំណាងកុមារ និងយុវជនបានសំណូមពរឱ្យមានការសម្រួល ការប្រើប្រាស់ពាក្យពេចន៍ ដើម្បីឱ្យពួកគេងាយស្រួលយល់ និងទទួលបានព័ត៌មានគ្រប់គ្រាន់។

បង្កើតឧបករណ៍ (**Tool**) ដើម្បីទប់ស្កាត់មាតិកាដែលមិនល្អ ៖ តំណាងកុមារ និងយុវជនបានសំណូមពរ ឱ្យមានការបង្កើតជាឧបករណ៍ (**Tool**) ដើម្បីទប់ស្កាត់ ឬប្រោះចេញនូវរាល់មាតិកាដែលមិនល្អនៅតាមបណ្ដាញសង្គម មានដូចជា វីដេអូអាសអាភាស ឬមាតិកាមិនសម្បរម្យផ្សេងៗដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារនៅតាមប្រព័ន្ធអនឡាញ។



## ២.យុត្តិធម៌ព្រហ្មទណ្ឌ

ការដាក់ពិន័យឱ្យធ្ងន់ធ្ងរ ៖ តំណាងកុមារនិងយុវជន បានសំណូមពរឱ្យមានការដាក់ទោសធ្ងន់ធ្ងរទៅលើជនល្មើសដែលបានប្រព្រឹត្តការរំលោភបំពានកុមារនៅតាមប្រព័ន្ធអនឡាញ និងសុំអោយមាន ការសហការពីក្រុមហ៊ុនបណ្តាញសង្គម ឱ្យមានការដកហូតឬ លុបចោលនូវមាតិកាដែលមិនល្អ ទាំងនោះចេញពីបណ្តាញសង្គម។

ការអនុវត្តន៍បែបកុមារមេត្រី ៖ តំណាងកុមារនិងយុវជន បានសំណូមពរអោយការឆ្លើយតប ចំពោះបញ្ហា**OCSE** អោយមានលក្ខណៈជាប្រព័ន្ធនិងមានកុមារមេត្រី(ដូចជាការបង្កើនចំនួន ប៉ូលីសជាស្ត្រីនៅតាមសហគមន៍) ដើម្បីអោយកុមារមានទំនុកចិត្តក្នុងការរាយការណ៍ និងដំណើរ ការស៊ើបអង្កេត។



## ៣.ការជួយជនរងគ្រោះ

យន្តការរាយការណ៍ ៖ តំណាងកុមារ និងយុវជន បានសំណូមពរឱ្យមានយន្តការរាយការណ៍ ឬលេខទាន់ហេតុការណ៍សម្រាប់រាយការណ៍ពីបញ្ហាOCSEអោយច្បាស់លាស់។ ពួកគេក៏សុំឱ្យមានការឆ្លើយតប និងការគាំទ្រប្រកបដោយប្រសិទ្ធភាពបន្ទាប់ពីការរាយការណ៍ និងរក្សាការសម្ងាត់ជូនជនរងគ្រោះ។



ការគាំទ្រ ៖ តំណាងកុមារ និងយុវជនបានសំណូមពរឱ្យមានការគាំទ្រពីគ្រួសារ មិត្តភក្តិ និងអាជ្ញាធរតាមមូលដ្ឋានផ្នែកផ្លូវចិត្តព្រោះវាមានសារៈសំខាន់ក្នុងការបង្កើតបរិយាកាសមួយដែលមាន  ការគាំទ្រដល់ជនគ្រោះ និងលុបបំបាត់ចោលនូវវប្បធម៌ស្តីបន្ទោសជនរងគ្រោះ។

ការផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព ៖ តំណាងកុមារ និងយុវជនបានសំណូមពរឱ្យមានការផ្សព្វផ្សាយ និងកសាងសមត្ថភាពដល់មន្ត្រីមូលដ្ឋានបន្ថែមក្នុងការផ្តល់សេវាគាំទ្រដល់រងគ្រោះ។

## ៤.សុវត្ថិភាពសហគមន៍

**ពង្រឹងភាពអង់អាចដល់កុមារ៖** តំណាងកុមារ និងយុវជនបានសំណូមពរឱ្យមានការផ្តល់ឱកាសសម្រាប់ពួកគេក្នុងការចូលរួមការពារ និងកម្មវិធីមិត្តអប់រំមិត្ត។ ពួកគេក៏បានជំរុញឱ្យមានការ ផ្សព្វផ្សាយកម្មវិធីមិត្តអប់រំមិត្តបន្ថែមដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហា OCSE ដល់កុមារ និងយុវជន។

**ការចែករំលែកព័ត៌មាន ៖** តំណាងកុមារ និងយុវជនបានសំណូមពរឱ្យមានការចែករំលែកព័ត៌មាន ការអប់រំ សម្ភារៈផ្សព្វផ្សាយឱ្យមានលក្ខណៈបែបកុមារមេត្រី ដើម្បីឱ្យកុមារងាយស្វែងរកសេវាគាំទ្រប្រកបដោយទំនុកចិត្ត និងយល់ដឹងពីបញ្ហា OCSE។





## ៥.វិស័យឯកជន

**ការគ្រប់គ្រងមាតិកា ៖** តំណាងកុមារ និងយុវជនបានសំណូមពរឱ្យក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល កំណត់គោលការណ៍ក្នុងការកំណត់អាយុសំរាប់អ្នកប្រើប្រាស់ និងច្រោះចេញនូវមាតិកាដែល មិនសមរម្យដូចជាវីដេអូអាសអាភាស និងរូបភាព-សម្ភារៈរំលោភបំពានកុមារ។

**ការរក្សាសុវត្ថិភាពទិន្នន័យ ៖** តំណាងកុមារ និងយុវជនបានសំណូមពរឱ្យក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល បង្កើនការការពារទិន្នន័យឯកជនភាពរបស់ពួកគេ និងមានការបកប្រែលក្ខខណ្ឌនៃការប្រើប្រាស់ជាភាសាខ្មែរ និងមានយន្តការសម្រាប់រាយការណ៍ជាភាសាខ្មែរ។

**បង្កើនការអប់រំ និងផ្សព្វផ្សាយ៖** ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលគួរតែមានការផ្ញើរជាសារ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហានៃការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញឱ្យដូចជាការផ្ញើរសាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀនផងដែរជាពិសេសនៅថ្ងៃបុណ្យជាតិនានា ហើយពួកគេក៏បានសំណូមពរក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល បង្កើតជាហ្គេមដើម្បីលើកកម្ពស់ ការយល់ដឹងពីបញ្ហានៃការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញផងដែរ។

## ៦.ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង

**ការរាយការណ៍ ៖** តំណាងកុមារ និងយុវជនបានសំណូមពរឱ្យប្រព័ន្ធផ្សព្វផ្សាយបង្កើនការផ្សព្វផ្សាយ ពីបញ្ហានៃការរំលោភបំពានកុមារតាមប្រព័ន្ធអានឡាញ និងបង្កើនកិច្ចសហការដើម្បីឱ្យយន្តការរាយការណ៍ឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះ និងសាធារណជន។ យើងទាំងអស់គ្នាចូលរួមបង្កើតពិភពអនឡាញមួយដែលមានសុវត្ថិភាពសម្រាប់កុមារ!



យើងទាំងអស់គ្នាចូលរួម
បង្កើតពិភពអនឡាញមួយ
ដែលមានសុវត្ថិភាព
សម្រាប់កុមារ!

# ជំហានបន្ទាប់

ឯកសារនេះមានគោលបំណងប្រមូលយកនូវមតិយោបល់ និងសំណូមពររបស់តំណាងកុមារ និងយុវជន ដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីជាឯកសារយោងសំរាប់ការចាប់ផ្តើមវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និង ឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអឡាញ២០២១-២០២៥ និងការរៀបចំផែនការជាតិស្តីពីការទប់ ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារ២០២៤-២០២៨ និងធានាថាសំឡេងរបស់កុមារ ត្រូវបានទទួលការយកចិត្តទុកដាក់យ៉ាងខ្ពស់បំផុតដើម្បីឱ្យការបង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញកាន់តែមានប្រសិទ្ធភាព។

## សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

លោកស្រី Zoe de Melo ប្រធានកម្មវិធី តាមរយៈអ៊ីម៉ែល៖ z.demelo@tdh.nl
លោកលាប ឆេងឡា មន្ត្រីសម្របសម្រួលគម្រោង តាមរយៈអ៊ីម៉ែល៖ c.leap@tdh.nl

Terre des Hommes Netherlands